**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ១៦៤ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការបញ្ចប់ស្ថានភាពគតិយុត្តិរាជាយស្ម័យយានកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

www.pheakdeylaw.com

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា ១ :** ត្រូវបានបញ្ចប់ស្ថានភាពគតិយុត្តិរាជាយស្ម័យយានកម្ពុជា ដែលជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ចាប់ពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ តទៅ។

**មាត្រា ២ :** រំសាយក្រុមប្រឹក្សាភិបាលប្រចាំរាជាយស្ម័យយានកម្ពុជា រំសាយប្រធានអគ្គនាយករាជាយស្ម័យយានកម្ពុជា និងរំសាយមន្ត្រីត្រួតពិនិត្យរដ្ឋអមរាជាយស្ម័យយានកម្ពុជា ចាប់ពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ តទៅ។

**មាត្រា ៣ :** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវទទួលបន្ទុកដោះស្រាយបន្តរាល់បំណុលត្រូវទារ និងត្រូវសង ដែលនៅសេសសល់ទាំងអស់ រវាងរាជាយស្ម័យយានកម្ពុជា និងបណ្តាក្រុមហ៊ុន ស្ថាប័ននានា និងអតិថិជន។

**មាត្រា ៤ :** ថវិកាដែលសល់ក្នុងគណនី និងបេឡារបស់រាជាយស្ម័យយានកម្ពុជា ត្រូវផ្ទេរចូលថវិការដ្ឋ និង បិទរាល់គណនីធនាគារទាំងអស់របស់រាជាយស្ម័យយានកម្ពុជា ចាប់ពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ តទៅ។

**មាត្រា ៥ :** រាជាយស្ម័យយានកម្ពុជា ត្រូវប្រគល់ត្រា និងឯកសារពាក់ព័ន្ធទាំងអស់ រួមទាំងឯកសារក្នុងកុំព្យូទ័រ មកក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីរក្សាទុក។

**មាត្រា ៦ :** អនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតរាជាយស្ម័យយានកម្ពុជាជាសហគ្រាសសាធារណៈ និងបទប្បញ្ញត្តិទាំងឡាយដែលណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ចាប់ពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ តទៅ។

**មាត្រា ៧ :** ផ្ទេរឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានអគ្គនាយករាជាយស្ម័យយានកម្ពុជា និងមន្ត្រីបុគ្គលិក និងកម្មករទាំងអស់របស់រាជាយស្ម័យយានកម្ពុជា សរុបចំនួន ១១០២ នាក់ អោយចូលបំរើការងារ ក្នុងក្របខ័ណ្ឌនៃក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ៨ :** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីដោះស្រាយបន្តបើកផ្តល់ប្រាក់បៀវត្សជូនដល់មន្ត្រី បុគ្គលិក និងកម្មកររាជាយស្ម័យយានកម្ពុជាទាំងអស់ រហូតដល់កិច្ចដំណើរការនៃឯកជនភាវូបនីយកម្មរាជាយស្ម័យយានកម្ពុជា ត្រូវបានចប់សព្វគ្រប់ជាស្ថាពរ។

**មាត្រា ៩ :** ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងបន្តរាល់ប្រតិបត្តិការរបស់ផ្លូវដែក រហូតដល់ពេលផ្ទេរប្រតិបត្តិការផ្លូវដែកទាំងស្រុង ទៅអោយក្រុមហ៊ុនសម្បទានិក តាមកិច្ចព្រមព្រៀងសម្បទានរាជាយស្ម័យយានកម្ពុជា។

**មាត្រា ១០ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

www.pheakdeylaw.com

**មាត្រា ១១:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋានគ្រប់ក្រសួង- ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

*- ក្រសួងព្រះបរមរាជវាំង*

*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*- អគ្គលេខាធិការរាជរដ្ឋាភិបាល*

*- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*

*- ដូចមាត្រា ១១*

*- រាជកិច្ច* ✓

www.pheakdeylaw.com